ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង
ខេត្តឧត្តរមានជ័យ
សំណុំរឿងព្រហ្មទណ្ឌលេខ ១០៩
ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩
សាលក្រមលេខ ០៥ "ច"
ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តឧត្តរមានជ័យ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការដែលប្រកាសឱ្យប្រើប្រាស់តាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៤ និងបានបើកសវនាការជំនុំជម្រះជាសាធារណៈនាថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ដោយមានសមាសភាពដូចតទៅ:

## ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក ចៅក្រមប្រឹក្សា
លោក ចៅក្រមប្រឹក្សា

## តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តឧត្តរមានជ័យ

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តឧត្តរមានជ័យ

## មេធាវី

លោក [redacted] និងលោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] រ័ត្ន ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១០៩ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទឈ្មោះ [redacted] រ័ត្ន ភេទប្រុស អាយុ២៦ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើតខេត្តកំពត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តឧត្តរមានជ័យ ប្រពន្ធឈ្មោះ [redacted] ស្រីមុំ ឪពុកឈ្មោះ [redacted] អ៊ុន (ស្លាប់) ម្តាយឈ្មោះ [redacted] ទូច (រស់) ទោសពីមុន គ្មាន (ក្នុងឃុំ) ជាប់ចោទពីបទ **ឃាតកម្ម** ប្រព្រឹត្តនៅភូមិស្រែក្រសាំង ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ។

**-បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ០៧៤ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ១២៧ ដសសព ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ។

**-បានឃើញ** ដីកាដំណោះស្រាយ (បញ្ជូនសំណុំរឿងទៅជំនុំជម្រះ) លេខ ១២១ ពស.ព្រទ/១៩ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តឧត្តរមានជ័យ។

**-បានឃើញ** សំណុំរឿងជំនុំជម្រះលេខ ១៥០ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តឧត្តរមានជ័យ។



Scanned with CamScanner

-បានឃើញ ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខ ១៥២ ដចត ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ប្រធានសាលាដំបូងខេត្តឧត្តរមានជ័យ។

## ដំណាលរឿងហេតុមានដូចតទៅ៖

កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ វេលាម៉ោង ១៣ និង៤០នាទី កម្លាំងមូលដ្ឋានកងរាជអាវុធហត្ថស្រុកត្រពាំងប្រាសាទ បានចុះបង្ក្រាបករណីឃាតកម្ម នៅភូមិស្រែក្រសាំង ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ដោយឃាត់បានជនសង្ស័យឈ្មោះ [redacted] រ័ត្ន ភេទប្រុស អាយុ២៦ឆ្នាំ ដោយឈ្មោះ [redacted] រ័ត្ន បានយកកាំបិតផ្គាក់ ដងធ្វើអំពីឈើ ដែលមានប្រវែង៨៤សង់ទីម៉ែត្រ កាប់ទៅលើប្រពន្ធរបស់ខ្លួនឈ្មោះ [redacted] ស្រីមុំ ភេទស្រី អាយុ២៦ឆ្នាំ ត្រូវចំកខាងស្តាំចំនួន០១កាំបិត បណ្តាលឱ្យជនរងគ្រោះស្លាប់ភ្លាមៗនៅកន្លែងកើតហេតុតែម្តង។

## នាពេលសវនាការ

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] រ័ត្ន ភេទប្រុស អាយុ២៦ឆ្នាំ បានឆ្លើយថា នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៩ ខ្លួនបានធ្វើដំណើរពីខេត្តបន្ទាយមានជ័យ ក្នុងគោលបំណងមកភូមិស្រែក្រសាំង ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ដើម្បីទៅធ្វើស្រែ ធ្វើដំណើរដោយគោយន្តជាមួយប្រពន្ធកូន ហើយថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ ខ្លួនបានធ្វើដំណើរបន្តចេញពីអន្លង់វែងនៅវេលាម៉ោង៨ ទៅដល់ត្រពាំងប្រាសាទវេលាម៉ោង ១០ ខ្លួនបានប្រាប់ប្រពន្ធថាខ្លួនមិនស្រួលខ្លួន ខ្លួនចង់ទៅវត្តក្រោយមកប្រពន្ធឱ្យដេកបានមួយម៉ោង ក្រោយមកងើបមកងងឹតមុខ រួចបានកាប់សម្លាប់ប្រពន្ធ ដោយខ្លួនបានយកកាំបិតវែងទៅកាប់ប្រពន្ធ ដែលគេងជិតខ្លួនតែម្តង។ នៅពេលប្រព្រឹត្តខ្លួនមិនដឹងខ្លួននោះទេ លុះដល់ពេលក្រោយមកបានកន្លះម៉ោងក៏បានដឹងខ្លួនក៏សោកស្តាយ។ នៅពេលសម្លាប់ប្រពន្ធពេលខ្លះដឹងពេលខ្លះមិនដឹង នៅពេលដឹងខ្លួនវិញឃើញនៅកប្រពន្ធមានស្នាមចំនួន០២កាំបិត ខ្លួនទទួលស្គាល់ថាខ្លួនពិតជាបានសម្លាប់ប្រពន្ធផ្ទាល់មែន តែពេលសម្លាប់ខ្លួនបានដឹងខ្លួន និងមិនដឹងខ្លះ ខ្លួនស្រលាញ់ប្រពន្ធមិនដែលមានបំណងសម្លាប់នោះទេ ហើយនៅថ្ងៃកើតហេតុខ្លួនក៏មិនបានឈ្លោះគ្នាជាមួយប្រពន្ធនោះដែរ ដោយពេលនោះមានខ្មោចចូលខ្លួន ព្រោះនៅពេលខ្លួនមានអាយុ២៣ ទៅ២៤ឆ្នាំ ខ្លួនធ្លាប់មានខ្មោចចូល។ ខ្លួនមានកូនម្នាក់អាយុ០៤ឆ្នាំ បន្ទាប់ពីកាប់ប្រពន្ធស្លាប់ខ្លួនមានភាពសោកស្តាយខ្លាំងណាស់។

-តាមអំណានកំណត់ហេតុត្រួតពិនិត្យសាកសព លេខ ០១៧/២០១៩ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ របស់មូលដ្ឋានកងរាជអាវុធហត្ថស្រុកត្រពាំងប្រាសាទ ឃើញថា សាកសពរបួស ក្រោមដងកាំបិតខាងស្តាំប្រវែង៣សង់ទីម៉ែត្រ ក្រោមដងកាំបិតខាងឆ្វេង៤សង់ទីម៉ែត្រ ស្មាខាងឆ្វេង៥សង់ទីម៉ែត្រថ្ពាល់ខាងស្តាំដប់ពីសង់ទីម៉ែត្រ កញ្ចឹងកប្រវែងប្រាំពីរសង់ទីម៉ែត្រ ស្មាផ្នែកខាងក្រោយប្រវែងដប់មួយសង់ទីម៉ែត្រ សាកសពដេកផ្ងាក្បាលទៅទិសខាងជើងដៃស្តាំដាក់ពីលើក្បាលជើងសណ្តូកទៅទិសខាងត្បូង ដេកស្លាប់ក្នុងរោងសិប្បកម្ម ចំងាយប្រហែល ១០០ម៉ែត្រ ពីផ្លូវលំ។ តាមការសន្និដ្ឋានរបួសនេះកើតឡើងដោយសារ ជនសង្ស័យយកកាំបិតផ្គាក់កាប់ទៅលើសាកសព (ប្រពន្ធ) ចំនួន ០១កាំបិត។

-តាមអំណានកំណត់ហេតុទទួលវត្ថុចាប់យក លេខ ០៤៣ អ.យ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ រួមមាន កាំបិតចិតបន្លែមួយប្រវែង ២,៩ សង់ទីម៉ែត្រ និងកាំបិតផ្គាក់មួយមានប្រវែង ៨,៤ សង់ទីម៉ែត្រ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា បន្ទាប់ពីបានស្តាប់ការពិភាក្សាដេញដោល បន្ទាប់ពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ បន្ទាប់ពីបានស្តាប់អំណានកំណត់ហេតុពិនិត្យសាកសព និងបន្ទាប់ពីបានស្តាប់អំណានកំណត់ហេតុ



Scanned with CamScanner

ទទួលវត្ថុចាប់យក រួចមក ដូច្នេះតំណាងអយ្យការសូមរក្សាបទចោទទុកនៅដដែល ដោយស្នើសុំឱ្យផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] រ័ត្ន ភេទប្រុស អាយុ២៦ឆ្នាំ ពីបទ ឃាតកម្ម តាមបញ្ញត្តិមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ។

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានកំណត់ហេតុពិនិត្យសាកសព
- ក្រោយពីបានស្តាប់អំណានកំណត់ហេតុទទួលវត្ថុចាប់យក
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ និងការប្តឹងសុំ

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា**

១/.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] រ័ត្ន ភេទប្រុស អាយុ២៦ឆ្នាំ បានឆ្លើយថា នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ ខ្លួនទទួលស្គាល់ថាខ្លួនពិតជាបានសម្លាប់ប្រពន្ធផ្ទាល់មែន។ ចំពោះចម្លើយដែលជនជាប់ចោទបានឆ្លើយថា ពេលសម្លាប់ខ្លួនបានដឹងខ្លួន និងមិនដឹងខ្លះ ដោយពេលនោះមានខ្មោចចូលខ្លួន ព្រោះនៅពេលខ្លួនមានអាយុ២៣ ទៅ២៤ឆ្នាំ ខ្លួនធ្លាប់មានខ្មោចចូល ជាចម្លើយដែលជនជាប់ចោទឆ្លើយក្នុងគោលបំណងគេចវេសពីការទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន និងមានភស្តុតាង ឬសាក្សីណាមួយយកមកបញ្ជាក់ឱ្យតុលាការជឿជាក់បានថា ពេលធ្វើសកម្មភាពនោះ គឺជនជាប់ចោទពិតជាមានខ្មោចចូលមែននោះទេ ដូច្នេះគប្បីតុលាការធ្វើការពិចារណា។

២/.តាមអំណានកំណត់ហេតុពិនិត្យសាកសព លេខ ០១៣/២០១៩ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ របស់មូលដ្ឋានកងរាជអាវុធហត្ថស្រុកត្រពាំងប្រាសាទ ឃើញថា សាកសពរបួស ក្រោមដងកាំបិតខាងស្តាំប្រវែង៣សង់ទីម៉ែត្រ ក្រោមដងកាំបិតខាងឆ្វេង៤សង់ទីម៉ែត្រ ស្នាខាងឆ្វេង៥សង់ទីម៉ែត្រផ្ទាល់ខាងស្តាំដប់ពីសង់ទីម៉ែត្រ កញ្ចឹងកប្រវែងប្រាំពីរសង់ទីម៉ែត្រ ស្នាផ្នែកខាងក្រោយប្រវែងដប់មួយសង់ទីម៉ែត្រ សាកសពដេកផ្ងាក្បាលទៅទិសខាងជើងដៃស្តាំដាក់ពីលើក្បាលជើងសណ្តូកទៅទិសខាងត្បូង ដេកស្លាប់ក្នុងរោងសិប្បកម្ម ចំងាយប្រហែល ១០០ម៉ែត្រ ពីផ្លូវលំ។ តាមការសន្និដ្ឋានរបួសនេះកើតឡើងដោយសារ ជនសង្ស័យយកកាំបិតផ្គាក់កាប់ទៅលើសាកសព (ប្រពន្ធ) ចំនួន ០១កាំបិត ដោយយោងតាមកំណត់ហេតុទទួលវត្ថុចាប់យក លេខ ០៤៣ អ.យ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ ឃើញថា កាំបិតផ្គាក់មួយមានប្រវែង ៨,៤ សង់ទីម៉ែត្រ ជារបស់ជនជាប់ចោទឈ្មោះ [redacted] រ័ត្ន ដូច្នេះអាចបញ្ជាក់ឱ្យឃើញថា កាំបិតផ្គាក់ដែលកាប់មកលើជនរងគ្រោះ (ប្រពន្ធ) គឺជារបស់ជនជាប់ចោទឈ្មោះ [redacted] រ័ត្ន គប្បីតុលាការធ្វើការពិចារណា។

៣/.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា បន្ទាប់ពីបានស្តាប់ការពិភាក្សាដេញដោល បន្ទាប់ពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ បន្ទាប់ពីបានស្តាប់អំណានកំណត់ហេតុពិនិត្យសាកសព និងអំណានកំណត់ហេតុទទួលវត្ថុចាប់យក រួចមក ដូច្នេះតំណាងអយ្យការសូមរក្សាបទចោទទុកនៅដដែល ដោយស្នើសុំឱ្យផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] រ័ត្ន ភេទប្រុស អាយុ២៦ឆ្នាំ ពីបទ ឃាតកម្ម តាមបញ្ញត្តិមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការធ្វើការពិចារណា។

៤/.តាមអំណានចម្លើយរបស់ជនជាប់ចោទ តាមអំណានកំណត់ហេតុពិនិត្យសាកសព តាមសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ មានភាពស៊ីសង្វាក់គ្នា អាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] រ័ត្ន ភេទប្រុស អាយុ២៦ឆ្នាំ ពិតជាបានធ្វើសកម្មភាពដោយយកកាំបិតទៅកាប់លើប្រពន្ធរបស់ខ្លួនបណ្តាល



Scanned with CamScanner

ឱ្យស្លាប់ ប្រាកដមែន ដែលអំពើនេះត្រូវបានច្បាប់កំណត់ថាទុកថាជាបទល្មើសព្រហ្មទណ្ឌ ពីបទ ឃាតកម្ម តាមបញ្ញត្តិមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការធ្វើការពិចារណា។

៥/.ជនជាប់ចោទមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវរាល់អំពើ និងសកម្មភាពរបស់ខ្លួនផ្អែកតាមអង្គហេតុ និងការស្រាវជ្រាវប្រមូលភស្តុតាងនៅដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរ អាចឱ្យតុលាការជឿបានថា ជនជាប់ចោទពិតជាមានចេតនាទុច្ចរិតក្នុងការប្រព្រឹត្តអំពើដូចការចោទប្រកាន់ប្រាកដមែន គប្បីតុលាការពិចារណា។

៦/.អំពើរបស់ជនជាប់ចោទ ធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយរបស់សង្គម។

៧/.ជនជាប់ចោទមានស្មារតីគ្រប់គ្រាន់ក្នុងពេលប្រព្រឹត្ត និងយល់ដឹងពីលទ្ធផលក្រោយពីប្រព្រឹត្តរួច និងពុំមានភស្តុតាងណាមួយបញ្ជាក់ថាជននេះមានវិប្បល្លាសស្មារតីឡើយ។

៨/.មានភស្តុតាង និងធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] វ័ត្ត ភេទប្រុស អាយុ២៦ឆ្នាំ ពីបទ ឃាតកម្ម ប្រព្រឹត្តនៅភូមិស្រែក្រសាំង ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ។

៩/.វត្ថុតាងរួមមាន កាំបិតចិតបន្លែមួយប្រវែង ២,៩ សង់ទីម៉ែត្រ និងកាំបិតផ្គាក់មួយមានប្រវែង ៨,៤ សង់ទីម៉ែត្រ គប្បីតុលាការរឹបអូសជាទ្រព្យសម្បត្តិរបស់រដ្ឋស្របតាមបញ្ញត្តិមាត្រា ៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

១/.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] វ័ត្ត ភេទប្រុស អាយុ២៦ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ១០ (ដប់) ឆ្នាំ ក្នុងអង្គហេតុ ពីបទ ឃាតកម្ម ប្រព្រឹត្តនៅភូមិស្រែក្រសាំង ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ។

២/.វត្ថុតាងរួមមាន កាំបិតចិតបន្លែមួយប្រវែង ២,៩ សង់ទីម៉ែត្រ និងកាំបិតផ្គាក់មួយមានប្រវែង ៨,៤ សង់ទីម៉ែត្រ សម្រេចរឹបអូសជាទ្រព្យសម្បត្តិរបស់រដ្ឋស្របតាមបញ្ញត្តិមាត្រា ៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ។

៣/.សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ នៅចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វ័ត្ត ភេទប្រុស អាយុ២៦ឆ្នាំ ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ៥ កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ឧត្តរមានជ័យ, ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

**ក្រឡាបញ្ជីសវនាការ**

[redacted]

[redacted]